របាយការណ៍សង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ខែ កញ្ញា ឆ្នាំ ២០១២

តំណាងជាស្ត្រីក្នុងវិស័យនយោបាយ និងប្រព័ន្ធបោះឆ្នោតបរិមាណភាគយេនឌ័រ

សេចក្តីផ្តើម

របាយការណ៍សង្ខេបនេះផ្តល់នូវទិដ្ឋភាពទូទៅនៃប្រព័ន្ធបោះឆ្នោតបរិមាណភាគ ដែលត្រូវបានអនុវត្តន៍ដោយបណ្តាប្រទេសមួយចំនួនដើម្បីលើកកម្ពស់ភាពជាតំណាងរបស់ស្ត្រីក្នុងវិស័យនយោបាយ ដោយវិភាគអំពីអត្ថប្រយោជន៍ដ៏សំខាន់ និងផ្តល់ជាអនុសាសន៍សម្រាប់ការអនុវត្តនូវប្រព័ន្ធបែបនេះនៅក្នុងប្រទេសកម្ពុជា ដើម្បីបញ្ជាក់អំពីកង្វះភាពជាតំណាងរបស់ស្ត្រីក្នុងវិស័យនយោបាយជាតិ និងថ្នាក់ក្រោមជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា "រដ្ឋាភិបាល" បានប្តេជ្ញាលើកកម្ពស់សមភាពយេនឌ័រ តាមរយៈចំណុចទី ៧ នៃគោលដៅទី ៣ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា "គ.អ.ស.ក ៣" ដែលព្យាយាម "លុបបំបាត់គំលាតយេនឌ័រនៅក្នុងកិច្ចការរដ្ឋាភិបាល" ដោយបង្កើនសមាមាត្រនៃអាសនរបស់ស្ត្រីនៅក្នុងស្ថាប័នរដ្ឋាភិបាល និងរដ្ឋបាលនានា[1]។ គោលដៅគឺលើកកម្ពស់ភាពជាតំណាងរបស់ស្ត្រីឲ្យដល់កម្រិតអប្បបរមា ៣០ភាគរយនៅរដ្ឋសភាជាតិ និង ព្រឹទ្ធសភា និង ឲ្យដល់កម្រិតអប្បបរមា ២៥ភាគរយនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ នៅឆ្នាំ២០១៥ ។ ការប្តេជ្ញាទាំងនេះត្រូវបានបង្ហាញតាមរយៈឯកសារគោលនយោបាយរបស់រដ្ឋាភិបាលនានាដូចជា៖ ផែនការនារីរតន: ទី១-៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដំណាក់កាលទី ១ និងទី២ "ផ.យ.អ.ជ" ដែលសុទ្ធតែផ្តល់នូវទិដ្ឋភាពរួមជាច្រើនសម្រាប់ជាគោលដៅ សកម្មភាព សូចនាករនៃការត្រួតពិនិត្យ និងធនធានសម្រាប់ប្រតិបត្តិដើម្បីលើកកម្ពស់សមភាពយេនឌ័រ[2] ។

ថ្វីបើមានការប្តេជ្ញាបែបនេះក្តី ស្ត្រីនៅតែខ្វះភាពជាតំណាងក្នុងវិស័យនយោបាយ ដោយកម្រិតនៃភាពជាតំណាងស្ត្រីនៅក្នុងស្ថាប័នមួយចំនួនមានការថយចុះនៅពេលបោះឆ្នោតថ្មីៗនេះ ។ នៅឆ្នាំ ២០០៣ ភាពជាតំណាងស្ត្រីនៅក្នុងបញ្ជីបេក្ខភាពសម្រាប់ការបោះឆ្នោតរដ្ឋសភាជាតិគឺមានចំនួន ២៧ភាគរយ ប៉ុន្តែបានធ្លាក់ចុះនៅត្រឹមតែ ១២,២ ភាគរយនៅក្នុងការបោះឆ្នោតឆ្នាំ ២០០៨ ដោយកម្រិតភាពជាតំណាងស្ត្រី នៅក្នុងស្ថាប័នរដ្ឋសភាជាទូទៅធ្លាក់ចុះមកនៅត្រឹមតែ ២២ភាគរយ ។ នៅព្រឹទ្ធសភាជាតិ ភាពជាតំណាងស្ត្រីគឺមាននៅតែចំនួន ១៤,៧៥ ភាគរយតែប៉ុណ្ណោះ ក្នុងរយៈពេល ១៣ឆ្នាំចុងក្រោយនេះ [3]។ កម្រិតនៃភាពជាតំណាងស្ត្រីនៅថ្នាក់ក្រោមជាតិក៏បង្ហាញអំពីតម្រូវការចាំបាច់ជា

---

[1] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំកម្ពុជា,២០១២, 'What is the difference between the Millennium Development Goals and the Cambodia Millennium Development Goals?' http://www.un.org.kh/undp/mdgs/cambodian-mdgs/what-are-the-cambodia-millennium-development-goals[រកបាននៅថ្ងៃទី ០៤ខែកញ្ញា ឆ្នាំ ២០១២]។

[2]ក្រសួងកិច្ចការនារី, "នារីរតន:ទី ៣", (២០០៩)ទំព័រទី ១៥-១៦, រដ្ឋាភិបាល, "ផ.យ.អ.ជ ១", (២០០៦),ទំព័រទី ៥, និង "ផ.យ.អ.ជ.២", (២០១០), ទំព័រទី ii-iv

[3]ការវិភាគទិន្នន័យទាំងមូលអាចរកបាននៅក្នុងhttp://www.sithi.org/temp.php?url=commune_election.php&tab_id=1&

យន្តការសកម្មភាពវិជ្ជមានផងដែរ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាពេលថ្មីៗនេះ ស្ត្រីដែលជាប់ឆ្នោតគឺមានតែ ១៧,៧៩ ភាគរយប៉ុណ្ណោះនៃតំណែងរបស់ក្រុមប្រឹក្សាសរុប ពោលគឺមានស្ត្រីត្រឹមតែ ៥០១នាក់ប៉ុណ្ណោះ (តំណាងឲ្យតែ ០,៤៥ភាគរយ នៃបេក្ខជនសរុប) ត្រូវបានដាក់នៅលេខរៀងលំដាប់ទីមួយនៃបញ្ជីបេក្ខភាព [4]។ ស្ថិតិនេះបង្ហាញនូវកង្វះការអនុវត្តជាក់លាក់ចំពោះការប្តេជ្ញាដែលបានចែងនៅក្នុង គ.អ.ស.ក និង ជំរុញឲ្យដាក់ចេញនូវប្រព័ន្ធបោះឆ្នោតបរិមាណភាគដើម្បីកាត់បន្ថយគំលាតរវាងវោហារសាស្ត្ររបស់រដ្ឋាភិបាល និងតថភាពនៃនយោបាយ ។

របាយការណ៍សង្ខេបនេះសរសេរដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(“ម.ស.ម.ក”)ជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរព សិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងនយោបាយនៅក្នុងប្រទេសកម្ពុជា។

ប្រភេទនៃប្រព័ន្ធបរិមាណភាគ

ប្រព័ន្ធបរិមាណភាគគឺជាយន្តការសកម្មភាពទំនោរ (ឬការរើសអើងជាវិជ្ជមាន)ដែលតម្រូវជាភាគរយជាក់លាក់ចំពោះក្រុមថ្នាក់បន្ទាប់ក្នុងចំណោមចំនួនប្រជាជនទូទៅដើម្បីមានភាពជាតំណាងនៅក្នុងអង្គភាព ឬស្ថាប័នមួយ ។ ជាធម្មតា ភាគរយត្រូវបានកំណត់អាស្រ័យលើហានៈនៃភាពជាតំណាងបច្ចុប្បន្នរបស់ក្រុមមួយ និងគោលដៅពាក់ព័ន្ធនឹងការបង្កើនភាពជាតំណាងនៅក្នុងក្រុមនីមួយៗនោះ ។ ទោះជារបាយការណ៍សង្ខេបនេះផ្តោតលើប្រព័ន្ធបរិមាណភាគព្រោះតែប្រព័ន្ធនេះទាក់ទងនឹងការបង្កើនភាពជាតំណាងស្ត្រីក្នុងវិស័យនយោបាយ ប្រព័ន្ធបរិមាណភាគក៏អាចត្រូវបានអនុវត្តន៍ដើម្បីដោះស្រាយអំពីកង្វះភាពជាតំណាងនៃតំបន់ ជនជាតិដើម ភាសា ឬសាសនាភាគតិចជាដើម ។ ចំពោះករណីស្ត្រី ជាទូទៅបរិមាណភាគកំណត់គោលដៅជាក់លាក់ចំពោះស្ត្រី ដែលជាធម្មតាក្នុងទម្រង់នៃលក្ខខណ្ឌតម្រូវអប្បបរមា ចន្លោះពី ៣០ ទៅ ៥០ភាគរយនៃបញ្ជីបេក្ខជនជាស្ត្រី នៅក្នុងស្ថាប័នរដ្ឋសភា និងអង្គភាពរដ្ឋាភិបាលជាទៃទៀត[5] ប៉ុន្តែពេលខ្លះជាសមភាពយេនឌ័រ ក្នុងបរិមាណភាគ ៥០/៥០ ឬលក្ខខណ្ឌដែលភាពជាតំណាងមិនលើសចំនួនភាគរយជាក់លាក់រវាងភេទទាំងពីរ ។ ទោះជា ការស្រាវជ្រាវបានបង្ហាញថា បរិមាណភាគយេនឌ័រអាចអនុវត្តន៍បានក្នុងរាល់ទម្រង់នៃប្រព័ន្ធនយោបាយ រាប់ពីរបបលទ្ធិប្រជាធិបតេយ្យ ដល់របបផ្តាច់ការ[6] បរិមាណភាគគឺងាយស្រួលអនុវត្តន៍ក្នុងប្រព័ន្ធតំណាងតាមសមាមាត្រ “ត.ស” និងកាន់តែងាយស្រួលក្នុងប្រព័ន្ធ ត.ស ដែលអនុវត្តន៍បញ្ជីបក្សបិទ ជាជាងបញ្ជីបក្សចំហ [7]។

---

[4] ប្រភពៈក្រសួងកិច្ចការនារី http://mwa.gov.kh/en/progress-women-decission-making (រកបានកាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១២)

[5] អង្គការសហប្រជាជាតិ, នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម, ២០១០, " The World’s Women 2010: Trends and Statistics ", ទំព័រ ១១៦ http://unstats.un.org/unsd/demographic/products/Worldswomen/WW2010pub.htm [រកបានកាលពីថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១២]

[6] ឌ្រូដដាឡ្លីរ៉ាប់, “Electoral Gender Quotas: between Equality of Opportunity and Equality of Result” ទំព័រទី ៧៧ ក្នុងផ្ទៃក *Representation*, ២០០៧ វគ្គទី ៤៣ លេខ ២ ទំព័រ ៧៣-៩២

[7] វិទ្យាស្ថានទទួលបន្ទុកសន្តិសុខ, ខែមីនា ឆ្នាំ ២០០៩, “Strategies for Policymakers: Brigning Women into Government” ទំព័រទី ៣ http://www.huntalternatives.org/download/1648_bringing_women_into_government_mar_09_final.pdf [រកបានកាលថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១២]

មកទល់ឆ្នាំ ២០១០ យ៉ាងហោចណាស់មានប្រទេសចំនួន ៩០នៅទូទាំងសាកលលោក បានអនុវត្តប្រភេទមួយចំនួននៃការបោះឆ្នោតបរិមាណភាគយេនឌ័រដើម្បីដោះស្រាយអំពីកង្វះភាពជាតំណាងនៅក្នុង សភាជាន់ទាប ឬ សភាទោលនៃស្ថាប័នសភាជាតិ[8] របស់ពួកគេ។ ក្នុងចំណោមប្រទេសទាំងអស់ មាន ៣៣ ប្រទេសបានអនុវត្តប្រព័ន្ធបរិមាណភាគបេក្ខជនដោយបញ្ញត្តិច្បាប់ និង មាន ១៦ ប្រទេសផ្សេងទៀតបានអនុវត្តប្រព័ន្ធអាសនបម្រុង ។ ក្នុងចំណោមប្រទេសចំនួន ៥៤ យ៉ាងហោចណាស់ មានគណៈបក្សនយោបាយមួយចំនួនបានបញ្ចូលប្រព័ន្ធបរិមាណភាគបេក្ខជនដោយស្ម័គ្រចិត្ត ។ ខណៈពេលដែលបរិមាណភាគបេក្ខជន ទាំងដោយបញ្ញត្តិច្បាប់ និងស្ម័គ្រចិត្ត ភាគច្រើនមានវត្តមាននៅអាមេរិកឡាទីន និងអឺរ៉ុប ប្រព័ន្ធអាសនបម្រុងច្រើនតែអនុវត្តន៍នៅទ្វីបអាហ្វ្រិក និងអាស៊ី[9]តែប៉ុណ្ណោះ ។ ក្នុងចំណោមបណ្តាប្រទេសទាំង ១០នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ "អាស៊ាន" មានប្រទេសតែ ៣ ប៉ុណ្ណោះដែលអនុវត្តប្រភេទមួយចំនួននៃប្រព័ន្ធបរិមាណភាគ ក្នុងនោះមាន ប្រទេសឥណ្ឌូនេស៊ីអនុវត្តប្រព័ន្ធបេក្ខភាពបរិមាណភាគបញ្ញត្តដោយច្បាប់នៅសភាជាន់ទាប ប្រទេសហ្វីលីពីនអនុវត្តប្រព័ន្ធអាសនបម្រុងនៅកម្រិតថ្នាក់ក្រោមជាតិ និងបរិមាណភាគបេក្ខជនដោយស្ម័គ្រចិត្តដែលបានប្រើប្រាស់ដោយគណបក្សនយោបាយចំនួនពីរ និងប្រទេសថៃដែលមានគណបក្សនយោបាយមួយបានប្រើប្រាស់បរិមាណភាគបេក្ខភាពស្ម័គ្រចិត្ត[10] ។ ជាការកត់សម្គាល់ឃើញថាមានប្រព័ន្ធបរិមាណភាគច្រើនជាងមួយអាចត្រូវបានអនុវត្តនៅក្នុងបណ្តាប្រទេសមួយចំនួន ។ ប្រភេទសំខាន់ៗទាំងបីនៃប្រព័ន្ធបរិមាណភាគនឹងត្រូវពន្យល់នៅខាងក្រោម។

បរិមាណភាគបេក្ខជនស្ម័គ្រចិត្ត

បរិមាណភាគបេក្ខជនស្ម័គ្រចិត្ត អាចត្រូវបានអនុវត្តដោយគណបក្សនយោបាយនិមួយៗនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ក្នុងរូបភាពជាការប្តេជ្ញាចិត្តរបស់បក្សដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យនយោបាយ ។ ការស្រាវជ្រាវបានបង្ហាញថាគណបក្សដែលមាននិន្នាការមនោគមវិជ្ជាឆ្វេងនិយម ដូចជា គណបក្សសង្គមប្រជាធិបតេយ្យ គណបក្សសង្គមនិយម និងគណបក្សបៃតង ទំនងជាអាចដាក់បញ្ចូលនូវបរិមាណភាគស្ត្រីនៅក្នុងក្រមខណ្ឌរបស់គណបក្សរបស់គេ ប៉ុន្តែគណបក្សអភិរក្សនិយមមាននិន្នាការបដិសេធទំនោរយន្តការសកម្មភាពនេះ [11]។ បរិមាណភាគគណបក្សស្ម័គ្រចិត្តត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅបច្ចឹមប្រទេស ដែលគណបក្សនយោបាយមិនត្រឹមតែបញ្ចូលប្រព័ន្ធបរិមាណភាគនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណបក្សទេ តែថែមទាំងគោរពដូចៗគ្នាដែរ ។ ឧទាហរណ៍នៅប្រទេសស៊ុយអែត គណបក្សនយោបាយជាច្រើនបានប្រើប្រាស់បរិមាណភាគបេក្ខជនស្ម័គ្រចិត្ត ៥០ភាគរយ ហើយប្រទេសនេះបានសម្រេចស្ទើរតែមានសមភាព ដោយមានអត្រា ៤៥ ភាគរយ នៃភាពជាតំណាងស្ត្រីនៅក្នុងការបោះ

---

[8] ស្ថិតិបច្ចុប្បន្នភាពស្តីពីប្រព័ន្ធបរិមាណភាគគឺពិបាករក ខណៈពេលដែលប្រព័ន្ធបរិមាណភាគ ទាំងជាស្ម័គ្រចិត្ត និងអាណត្តិតែងតែត្រូវបានផ្លាស់ប្តូរ បន្ថែម ឬដកចេញ ។ ដូច្នេះស្ថិតិទាំងនេះត្រូវបានព្យាករណ៍ និងមិនឆ្លុះបញ្ចាំងអំពីស្ថានភាពបច្ចុប្បន្នច្បាស់លាស់នោះទេ ។ ព័ត៌មាននេះអាចរកបាននៅhttp://www.quotaproject.org/។

[9] អង្គការសហប្រជាជាតិ "The World's Women 2010: Trends and Statistics" ទំព័រ ១១៦

[10] គម្រោងបរិមាណភាគ ទិន្នន័យនេះអាចរកបាននៅ http://www.quotaproject.org/[រកបានកាលពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១២]

[11] ស្ទីណាឡាហ្ស៊ីរ៉ូដ និងវីតា ថាផន Designing for Equality: best-fit, medium-fit and non-favourable combinations of electoral systems and gender quotas ទំព័រ ៨ និងនៅក្នុង *International Institute for Democracy and Electoral Assistance* ឆ្នាំ ២០០៧ និងជាលីរ៉ាប់ Electoral Gender Quotas ទំព័រ ៧៩

ឆ្នោតសភាជាន់ទាប[12] ។ តាមរយៈការអនុម័តនូវបរិមាណភាគស្មើគ្រចិត្ត គណបក្សនយោបាយអាចបង្ហាញនូវការប្តេជ្ញាចិត្តដើម្បីដំណើរការគោលនយោបាយ និងជាក់បញ្ជូលដោយសមភាពនូវបេក្ខភាពជាស្ត្រីនៅគ្រប់កម្រិតនៃស្ថាប័នរដ្ឋាភិបាល ។

នៅពេលដែលគ្មានលក្ខខណ្ឌតាមផ្លូវច្បាប់ សម្រាប់គណបក្សអនុវត្តន៍ចំពោះក្រុមគោលដៅដែលបានកំណត់ទេ ទណ្ឌកម្មដែលគ្មានបញ្ញត្តិច្បាប់គឺខុសប្រក្រតី ។ ជាទ្រឹស្តី ផលប៉ះពាល់មិនមែនតាមផ្លូវច្បាប់អាចនឹងមានចំពោះកេរ្តិ៍ឈ្មោះរបស់គណបក្ស និង ការរងសម្ពាធពីគណបក្សដទៃ ឬសាធារណៈជន ដែលអាចបង្កើតជាឱកាសឲ្យគណបក្សមួយប្រឹងប្រែងអនុវត្តន៍ដើម្បីសម្រេចឲ្យបានជាផ្លូវការនូវបរិមាណភាគដែលបានប្រកាស ។ ទោះបីជាយ៉ាងណាក៏ដោយ គម្លាតរវាងបរិមាណភាគស្មើគ្រចិត្ត និងភាពជាតំណាងជាក់ស្តែងនៅក្នុងប្រទេសជាច្រើនបង្ហាញថាមានគណបក្សជាច្រើនដែលបានបញ្ចូលបរិមាណភាគយេនឌ័រស្មើគ្រចិត្តតែងតែខកខានមិនបានអនុវត្តន៍ប្រព័ន្ធនេះ ប្រសិនបើអនុវត្តទទួលបានផលប៉ះពាល់តិចតួចចំពោះភាពជាតំណាងស្ត្រីក្នុងវិស័យនយោបាយ ។ បន្ថែមពីលើនេះបរិមាណភាគស្មើគ្រចិត្ត ជារឿយៗត្រូវបានអនុវត្តដោយគណបក្សនយោបាយតែមួយ ឬចំនួនតិចតួចតែប៉ុណ្ណោះ នៅក្នុងប្រទេសមួយ ដែលបង្ហាញអំពីការកាន់តែធ្លាក់ចុះនៃឥទ្ធិពលនៅក្នុងប្រទេសដែលមានគណបក្ស ច្រើនប្រកួតប្រជែងគ្នាសម្រាប់ការបោះឆ្នោត ។

បរិមាណភាគបេក្ខជនបញ្ញត្តដោយច្បាប់

បរិមាណភាគបេក្ខជន អាចត្រូវបានកំណត់ជាលក្ខខណ្ឌកាតព្វកិច្ចនៅក្នុងក្របខណ្ឌគតិយុត្តរបស់ប្រទេស ដូចជា រដ្ឋធម្មនុញ្ញ ឬផ្នែកណាមួយនៃច្បាប់ស្តីពីការបោះឆ្នោត ។ នៅក្រោមប្រព័ន្ធបរិមាណភាគកាតព្វកិច្ចរាល់គណបក្សទាំងអស់ត្រូវបានកំណត់ដោយច្បាប់ ដើម្បីចុះបញ្ជីក្នុងអត្រាភាគរយជាក់លាក់នៃបេក្ខភាគជាស្ត្រីនៅក្នុងបញ្ជីរបស់គណបក្សរបស់ពួកគេ ។ ជាធម្មតាបរិមាណភាគត្រូវបានបញ្ញត្តចំពោះការបោះឆ្នោតសភាជាន់ទាប ឬសភាទោលនៃរដ្ឋសភា និង/ឬនៅកម្រិតថ្នាក់ក្រោមជាតិ ដែលជាទូទៅការបោះឆ្នោតប្រើប្រព័ន្ធបញ្ជីសមាមាត្រតំណាង ប៉ុន្តែជារឿយៗការបោះឆ្នោតសភាជាន់ខ្ពស់គឺធ្វើដោយប្រយោល ឬតាមរយៈការតែងតាំង ។ ភាគរយបរិមាណភាគគឺចន្លោះពី ៣០ភាគរយ ដូចនៅក្នុងប្រទេសអាហ្សង់ទីន និង ប្រទេសប្រេស៊ីល រហូតដល់ ៥០ភាគរយ ដូចនៅក្នុងប្រទេសបារាំង[13] ជាដើម។ បរិមាណភាគបេក្ខជនកំណត់ដោយច្បាប់ត្រូវបានអនុវត្តជាលើកដំបូងនៅទ្វីបអាមេរិកឡាទីន ប៉ុន្តែក៏មានអនុវត្តនៅផ្នែកនានានៃទ្វីបអឺរ៉ុបដែរ ដូចជា ប្រទេសបែលហ្ស៊ិក ប្រទេសបារាំង ប្រទេសអេស្ប៉ាញ និងតំបន់បាល់កាន និងនាពេលថ្មីៗនេះត្រូវបានប្រើប្រាស់នៅប្រទេសទីម័រខាងកើត និង ប្រទេសឥណ្ឌូនេស៊ីផងដែរ[14] ។ ការខកខានចំពោះការអនុវត្តន៍លក្ខខណ្ឌផ្លូវច្បាប់នេះអាចនាំឲ្យមានការដាក់ទណ្ឌកម្មដោយពិន័យជាប្រាក់ ការបដិសេធបញ្ជីគណបក្សដែលបានស្នើ ឬបដិសេធគុណវុឌ្ឍិរបស់បេក្ខជន ។

បរិមាណភាគបេក្ខជនបញ្ញត្តដោយច្បាប់ មិនរារាំងគណបក្សនយោបាយមិនឲ្យអនុវត្តន៍បរិមាណភាគបេក្ខជនស្មើគ្រចិត្តដែលកំណត់នូវភាគរយខ្ពស់ជាងបេក្ខជនស្ត្រីដែលបញ្ញត្តបរិមាណភាគត្រូវបានកំណត់ច្បាប់ឡើយ ។ ឧទាហរ-

---

[12] គម្រោងកូតា ទិន្នន័យអាចរកបាននៅក្នុង http://www.quotaproject.org/uid/countryview.cfm?id=157 [រកបាននៅថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១២]

[13] ដាលីរ៉ាប់ Electoral Gender Quotas ទំព័រ ៧៧-៧៩

[14] ដាលីរ៉ាប់ Electoral Gender Quotas ទំព័រ ៧៩ និង ៨៤ និង ដាលីរ៉ាប់ *How to Achieve the CMDG3* ទំព័រ ២៧

ណ៍ នៅប្រទេសម៉ិកស៊ិក បរិមាណភាគបញ្ញត្តដោយច្បាប់គឺក្នុងអត្រា ៤០ភាគរយត្រូវបានអនុវត្ត ទាំងនៅសភាជាន់ទាប និងព្រឹទ្ធសភា ប៉ុន្តែទោះបីជាយ៉ាងនេះក្តី គណបក្សបដិវត្តន៍ប្រពៃណី បានអនុវត្តនូវបរិមាណភាគ ៥០ភាគរយនៃស្ត្រីនៅក្នុងលក្ខន្តិក:របស់គណបក្ស[15] ។

ការកំណត់អាណត្តិបរិមាណភាគបញ្ជីបេក្ខជន

ក្រៅពីបរិមាណភាគបេក្ខជនបញ្ញត្តដោយច្បាប់ និងដោយស្ម័គ្រចិត្ត បណ្តាប្រទេស និងគណបក្សនយោបាយនានាអាចអនុវត្តយន្តការបន្ថែមដែលកំណត់ពីលំដាប់លេខរៀងបេក្ខជននៅលើបញ្ជីបេក្ខជន ។ ទាំងនេះត្រូវបានគេហៅថា "បរិមាណភាគទ្វេ" ឬ "ការកំណត់អាណត្តិ" ។ ដោយហេតុថា គណបក្សគ្រប់គ្រង ថាតើបេក្ខជនណាត្រូវដាក់នៅលេខរៀងខាងលើនៃបញ្ជី ប្រសិនបើគ្មានបញ្ញត្តិបន្ថែមទាំងនេះទេ ជារឿយៗ ស្ត្រីត្រូវបានដាក់នៅលេខរៀងខាងក្រោមនៃបញ្ជីដែលការណ៍នេះនាំឲ្យថយចុះនូវឱកាសទទួលបានអាសន ។ បញ្ហាគឺកាន់តែមានស្ថានភាពដុនដាបឡើងក្នុងការបោះឆ្នោតថ្នាក់ស្រុក ដោយមានចំនួនអាសនតិចតួចដែលបេក្ខជនមានលំដាប់លេខរៀងនៅខាងលើបញ្ជីមានឱកាសដើម្បីទទួលបានអាសន ដោយគណបក្សនយោបាយ ដើរតួនាទីជា "អ្នកយាមទ្វារ" ជារឿយៗនៅតែព្រងើយកន្តើយចំពោះការដាក់លំដាប់លេខរៀងស្ត្រីក្នុងតួនាទីថ្នាក់ខ្ពស់នៃបញ្ជីបេក្ខជន [16]។

អវត្តមានយន្តការបន្ថែមអាចមានការជាប់ពាក់ព័ន្ធយ៉ាងសំខាន់ ។ ឧទាហរណ៍ ខណៈដែលទាំងប្រទេសអាហ្សង់ទីន និងប្រទេសប្រេស៊ីល សុទ្ធតែមានបញ្ញត្តអំពីបរិមាណភាគបញ្ជីបេក្ខជនចំនួន ៣០ភាគរយ ប៉ុន្តែភាពជាតំណាងស្ត្រីនៅប្រទេសអាហ្សង់ទីនក្នុងសភាជាន់ទាបគឺមាន ៣៥ភាគរយ បើប្រៀបនឹង ៨.៨ភាគរយនៅក្នុងសភាជាន់ទាបនៃប្រទេសប្រេស៊ីល ។ ភាពខុសប្លែកគ្នាដែលគួរឲ្យចាប់អារម្មណ៍លើប្រសិទ្ធភាពរវាងប្រទេសទាំងពីរគឺប្រហែលជាមានភាពខុសគ្នាមួយចំនួននៅប្រទេសអាហ្សង់ទីន ពោលនៅប្រទេសប្រេស៊ីលគ្មានវិធានស្តីពីការកំណត់លំដាប់លេខរៀងបេក្ខជន ដែលនាំឲ្យគណបក្សនយោបាយនានា បន្តដាក់បេក្ខភាពស្ត្រីនៅលេខរៀងខាងក្រោមនៃបញ្ជីបេក្ខជនដូច្នេះមានការកេងចំណេញដាលក្ខណៈអវិជ្ជមានយ៉ាងទូលំទូលាយពីបរិមាណភាគយេនឌ័រ ៣០ភាគរយនេះ[17] ។

គណបក្សសង្គមប្រជាធិបតេយ្យស៊ុយអែត បានផ្តល់នូវគំរូល្អជាអត្ថប្រយោជន៍នៃបរិមាណភាគបេក្ខភាពទាំងពីរប្រភេទ (ករណីនេះបរិមាណភាគស្ម័គ្រចិត្ត ៥០/៥០) ជាមួយនឹង "ប្រព័ន្ធច្របាច់បញ្ចូល" ដោយមានបញ្ជីបេក្ខជនផ្សេងគ្នា រវាងបេក្ខភាពជាស្ត្រី និងបុរស ក្នុងចំនួនស្មើគ្នា បន្ទាប់មកដាក់បញ្ចូលគ្នាជាជម្រើសរវាងភេទទាំងពីរ ។ ជាលទ្ធផលនៃការអនុម័តយន្តការបញ្ជីបេក្ខជននៃបក្សសង្គមប្រជាធិបតេយ្យ ភាពជាតំណាងស្ត្រីសរុបនៅក្នុងសភាស៊ុយអែតគឺមានចន្លោះពី ៤៧ និង ៥០ភាគរយក្នុងការបោះឆ្នោតទូទៅចំនួនបួនដង ចាប់តាំងពីអនុវត្តន៍យន្តការនេះនៅក្នុងឆ្នាំ ១៩៩៣[18] ។ ទោះបី ថាតើបេក្ខជននៅលំដាប់លេខរៀងខាងលើជាបុរស ឬ ស្ត្រីនៅតែស្ថិតក្រោមការសម្រេចចិត្តរបស់គណបក្សដោយប្រើប្រព័ន្ធច្របាច់បញ្ចូល ផ្តល់ជាមធ្យោបាយក្នុងការធានាថាភាពជាតំណាងស្ត្រីមានការកើនឡើង ។ ក្រៅពីនេះវិធានដែលមានលក្ខណៈបត់បែនក៏ត្រូវបានអនុវត្តផងដែរ ដូចជាថា បេក្ខជនពីរនាក់ដំបូងមិនគួរ

---

[15] គម្រោងបរិមាណភាគ អាចរកបាននៅក្នុង http://www.quotaproject.org/uid/countryview.cfm?id=157 [រកបានកាលនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២]

[16] ដាលឺរ៉ាប់ How to Achieve CMDG3 ទំព័រ ១៥-១៦

[17] ដាលឺរ៉ាប់ "Electoral Gender Quotas" ទំព័រ ៨៥

[18] ដាលឺរ៉ាប់ និងហ្វ្រេដេនវ៉ែល Electoral Gender Quota Systems ទំព័រ ៧៥-៧៨

មានភេទដូចគ្នាទេ ឬថាក្នុងចំណោមក្រុមដែលត្រូវមកបន្តតំណែងនៃបេក្ខជនបួននាក់ ត្រូវមានបេក្ខជនជាស្ត្រីមិនតិចជាងពីរនាក់នោះទេ ។

បរិមាណភាគជាអាសនបម្រុង

បរិមាណភាគអាស្រ័យលើលទ្ធផល បម្រុងទុកភាគរយពិសេសនៃអាសនៅក្នុងស្ថាប័នសភា ឬរដ្ឋាភិបាលដទៃទៀតសម្រាប់ ស្ត្រីដើម្បីធានាថាសមាសភាពនៃស្ថាប័នពាក់ព័ន្ធមានតុល្យភាពយេនឌ័រ ។ ជាធម្មតា បរិមាណភាគអនុវត្តជាចំនួនលេខ មិនមែនជាភាគរយទេ ។ ប៉ុន្តែ នៅពេលដែលបញ្ចាក់ជាភាគរយ អត្ថិភាពនៃប្រព័ន្ធបរិមាណភាគអាសនបម្រុងគឺមានលក្ខណៈផ្សេងៗពីគ្នា ដោយចាប់ពី ៥ភាគរយនៅក្នុងប្រទេសនេប៉ាល់ រហូតដល់ ប្រមាណ ១៧ ភាគរយនៅប្រទេសប៉ាគីស្ថាន និង ១៨ភាគរយនៅប្រទេសអ៊ូហ្គង់ដា រហូតដល់ច្រើនបំផុត ២៧ភាគរយ និង ៣០ភាគ-រយនៅប្រទេសអាហ្គានីស្ថាន និង ប្រទេសរ៉្វាន់ដា ។ គ្មានប្រព័ន្ធអាសនបម្រុងណាមួយតម្រូវឲ្យមានសមភាព ៥០ ៥០ ភាគរយ ទេនៅលើសាកលលោកនេះ[19] ។ ជាធម្មតាប្រព័ន្ធអាសនបម្រុងត្រូវបានចាត់ទុកថាជាវិធានការដ៏មានប្រសិទ្ធភាពដើម្បីបង្កើន ឬជំរុញការចូលរួមរបស់ស្ត្រីឲ្យបានច្រើននៅក្នុងសង្គមបិតុនិយម[20] ។ ប្រព័ន្ធអាសនបម្រុងត្រូវបានគេប្រើប្រាស់ក្នុងស្ថាប័ននយោបាយដែលសមាជិកត្រូវបានគេបោះឆ្នោតដោយប្រយោល ឬតែងតាំង ដែលខុសពីការបោះឆ្នោតសមាមាត្រចេញពីបញ្ជីបេក្ខជន ដូច្នេះទាំងប្រព័ន្ធបរិមាណភាគពីបញ្ជីបេក្ខភាពស្ម័គ្រចិត្ត ឬអាណត្តិគឺពិបាកក្នុងការអនុវត្ត ។

ការពិភាក្សាដេញដោលអំពីយេនឌ័រ

ប្រព័ន្ធបោះឆ្នោតបរិមាណភាគនៅតែមានយន្តការផ្ទុយគ្នាជាមួយនឹងទឡ្លីករណ៍គាំទ្រនិងប្រឆាំងយ៉ាងខ្លាំងក្លា។ ទស្សនមួយនៃការពិភាក្សាដេញដោលគឺ ចំនួនតិចតួចរបស់ស្ត្រី ដែលចូលរួមយ៉ាងសកម្មក្នុង នយោបាយ ត្រូវបានគេមើលឃើញថាជាលទ្ធផលនៃកង្វះធនធាន និងការប្តេជ្ញាចិត្តរបស់ស្ត្រី ។ ការគិតរបៀបនេះត្រូវបានគេស្គាល់ថាជាម៉ូដែល "ដំហ៊ានតូច" ដោយសន្មត់ថាពេលណាមួយសមភាពយេនឌ័រនឹងសម្រេចបានដោយខ្លួនឯងនៅពេលដែលសង្គមមានការវិវឌ្ឍន ។ គ្មានសកម្មភាពអន្តរាគមន៍ណាមួយ ក្រៅពីការកសាងសមត្ថភាពគឺចាំបាច់ នៅពេលដែលដំណើរការឈានឆ្ពោះទៅរកសមភាពយេនឌ័រទូលំទូលាយ ត្រូវបានមើលឃើញថាដូចបន្តឆ្ពោះទៅមុខ ដោយការវិវឌ្ឍជាប្រចាំ ។ តាមរយៈទស្សនេះ គ្មានយុត្តិកម្មទំនោរទៅរកក្រុមមួយនៃបេក្ខជនដើម្បីជាប្រយោជន៍ដល់ក្រុមដទៃទេ ការអនុវត្តន៍ប្រព័ន្ធបរិមាណភាគគ្រាន់តែនាំឲ្យមានការរើសអើង និងភាពប្រឈមគ្នានៃគោលការណ៍ផ្តល់ឱកាស និង ការប្រព្រឹត្តិដោយសមភាពចំពោះបុគ្គលគ្រប់រូបតែប៉ុណ្ណោះ ។ ជាពិសេសប្រព័ន្ធអាសនបម្រុងតែងតែត្រូវបានរិះគន់ដោយក្រុមប្រឆាំង ដែលអះអាងថាវាជាការរើសអើងជាក់ស្តែងប្រឆាំងនឹងបុរស និងដើរតួជាអ្នកវិតក្កិតការប្រកួតប្រជែងតាមបែបលទ្ធិប្រជាធិបតេយ្យ និងសមត្ថភាពនិយម ។ ជាចុងក្រោយ ទស្សនេះបានអះអាងថា ស្ត្រីជាច្រើនមិនចង់ឲ្យគេបោះឆ្នោតឲ្យ ព្រោះតែពួកគេជាស្ត្រី និងថាបរិមាណភាគអាចផ្តល់សម្បទានដើម្បីសន្មត់ថាស្ត្រីត្រូវបានលើកកម្ពស់ឬបោះឆ្នោតដោយសារតែភេទ ជាជាងគុណវុឌ្ឍិ[21]របស់ពួកគេ ។

---

[19] ដាលឺរ៉ាប់ Electoral Gender Quotas ទំព័រ ៨៦

[20] Ibid.ដូចខាងលើ

[21] ដាលឺរ៉ាប់ និងហ្វេដេនវ៉ែល Electoral Gender Quota Systems ទំព័រ ១៨-១៩

ក្រៅពីនេះ ទស្សនផ្សេងទៀតបដិសេធនូវការសន្មត់ខាងលើដែលថា សមភាពយេនឌ័រនឹងវិឌ្ឍន៍ដោយស្វ័យប្រវត្តិ និងអះអាងថារចនាសម្ព័ន្ធសង្គម និងនយោបាយបច្ចុប្បន្នរើសអើងប្រឆាំងនឹងស្ត្រី និងរារាំងស្ត្រីមិនឲ្យចូលរួមនៅក្នុងរឿងនយោបាយ ។ ក្នុងទស្សននេះ ត្រូវបានគេស្គាល់ថាជាម៉ូដែល "ជំហានលឿន" ដែលថាបញ្ហាកង្វះភាពជាតំណាងស្ត្រីគឺមិនមែនដោយសារស្ត្រីខ្លួនឯងនោះទេ ប៉ុន្តែដោយសារប្រពៃណីដែលហួសសម័យ និងការដាក់ដោយឡែករបស់ស្ថាប័ន និង អង្គការនានាដោយបដិសេធឱកាសសមភាពរបស់ស្ត្រី បើទោះបីជាស្ត្រីមានគុណវុឌ្ឍិគ្រប់គ្រាន់ក៏ដោយ ។ បើទោះបីជាស្ត្រីប្រហែលជាត្រូវបានផ្តល់នូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដូចគ្នានឹងបុរសតាមផ្លូវច្បាប់ក្តី ប៉ុន្តែជាតថភាពជាក់ស្តែងស្ត្រីមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ ។ តាមទស្សនការបោះជំហានលឿន វិធានការសកម្មភាពទំនោរមួយចំនួន ដូចជា បរិមាណភាគយេនឌ័រ គឺជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍឆ្ពោះទៅមុខដើម្បីលើកកម្ពស់ភាពជាតំណាងស្ត្រីក្នុងវិស័យនយោបាយ ជាមួយការអនុវត្តបរិមាណភាគ ដើម្បីលើកទឹកចិត្តទប់ទល់នឹងឧបសគ្គរារាំងចំពោះស្ត្រីក្នុងប្រព័ន្ធនយោបាយបិតុនិយម ។ ពេលដែលប្រទេសមួយសម្រេចបាននូវដំណាក់កាលប្រកួតប្រជែងដោយយុត្តិធម៌ និងសមភាពរវាងបេក្ខជនបុរស និងស្ត្រី នោះប្រព័ន្ធបរិមាណភាគអាចឈប់អនុវត្តន៍បាន[22] ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

បច្ចុប្បន្ននេះគ្មានបទប្បញ្ញត្តិស្តីអំពីបរិមាណភាគយេនឌ័រអនុវត្តន៍ចំពោះបញ្ជីបេក្ខជន ឬ អាសនបម្រុងនៅក្នុងស្ថាប័នដែលធ្វើសេចក្តីសម្រេចចិត្តនៅក្នុងប្រទេសកម្ពុជាទេ ហើយគណបក្សនយោបាយនានាមកទល់នឹងពេលនេះនៅមានការព្រងើយកន្តើយក្នុងការអនុវត្តការប្តេជ្ញាចិត្ត ដោយការស្ម័គ្រចិត្តជាផ្លូវការកំណត់នៅក្នុងទម្រង់បរិមាណភាគនៅក្នុង លក្ខន្តិកៈគណបក្សរបស់ខ្លួន បើទោះបីជាកាលកំណត់ដើម្បីសម្រេចឲ្យបានគោលដៅសហសវត្សន៍ឆ្នាំ ២០១៥ ជិតមកដល់ហើយក្តី ហើយការបោះឆ្នោតសភាឆ្នាំ ២០១៣គឺជាឱកាសចុងក្រោយដើម្បីលើកកម្ពស់ភាពជាតំណាងស្ត្រីនៅមុនឆ្នាំ ២០១៥ ។ ការណ៍នេះគួសបញ្ជាក់អំពីអសមភាពរវាងការប្តេជ្ញាដ៏មានរោហាសាស្ត្ររបស់រដ្ឋាភិបាល និងការអនុវត្តពិតប្រាកដនៃសមភាពយេនឌ័រនៅក្នុងអង្គការនយោបាយ ។

ស្ថិតិបង្ហាញថា ប្រព័ន្ធបរិមាណភាគអាចមានផលប៉ះពាល់ជាវិជ្ជមានទៅលើកម្រិតនៃភាពជាតំណាងស្ត្រីនៅក្នុងនយោបាយ ។ ក្នុងចំណោមប្រទេសចំនួន ២៣ ដែលសម្រេចបាននូវភាពជាតំណាងស្ត្រីអប្បបរមា ៣០ភាគរយនៅក្នុងសភាជាន់ទាប ឬសភាទោល គឺមានតែ ១៨ប្រទេសទេដែលអនុវត្តន៍ប្រភេទមួយចំនួននៃបរិមាណភាគយេនឌ័រនៅពេលបោះឆ្នោតទាំងបរិមាណភាគបេក្ខជនស្ម័គ្រចិត្ត និងបញ្ញត្តដោយច្បាប់សម្រាប់គណបក្សនយោបាយ ឬប្រព័ន្ធអាសនបម្រុងមួយ [23]។ ពាក់កណ្តាលនៃរដ្ឋទាំងនេះភាគច្រើនជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសរ៉្វាន់ដាដែលមានភាពជាតំណាងស្ត្រីខ្ពស់បំផុតរហូតដល់ ៥៦,៣ភាគរយ [24]។ នេះបង្ហាញថាបរិមាណភាគយេនឌ័រមួយអាចអនុវត្តន៍បាននៅក្នុងដំណាក់កាលនានានៃការអភិវឌ្ឍនយោបាយ និងសង្គមសេដ្ឋកិច្ច ។ បន្ថែមពីលើនេះ

---

[22] ដាលើរ៉ាប់ និងហ្វេដេនវ៉ែល Electoral Gender Quota Systems ទំព័រ ២១-២២ និងដាលើរ៉ាប់ *How to Achieve the CMDG* ទំព័រ ៧-៨

[23] អង្គការសហប្រជាជាតិ, នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម The World's Women 2010: Trends and Statistics ឆ្នាំ ២០១០ ទំព័រ ១១៦ អាចរកបាននៅក្នុង: http://unstats.un.org/unsd/demographic/products/Worldswomen/WW2010pub.htm

[24] ដាលើរ៉ាប់ How to Achieve the CMDG ទំព័រ ២៤

ក្នុងចំណោមប្រទេសចំនួន១៥ ដែលមានស្ត្រីជាតំណាងខ្ពស់បំផុតនៅក្នុងសភានៅទូទាំងពិភពលោកក្នុងឆ្នាំ ២០១០ មានតែ១១ប្រទេសប៉ុណ្ណោះដែលប្រើប្រាស់ប្រព័ន្ធបរិមាណភាគ[25] ។

ដូចដែលគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីកេទ (“ស៊ីដរ”) បញ្ជាក់នៅក្នុងអនុ-សាសន៍ទូទៅ "សម្រេចឲ្យបានយ៉ាងតិចបំផុត" ចន្លោះពី ៣០ ទៅ ៣៥ភាគរយនៃភាពជាតំណាងស្ត្រីគឺមានសារសំខាន់ ដើម្បីផ្តល់នូវឥទ្ធិពលលើការពិភាក្សាស្តីពីរចនាសម្ព័ន្ធ និងមាតិកានៃកិច្ចពិភាក្សានយោបាយ និងសេចក្តីសម្រេចចិត្ត ជាសាធារណៈនានា [26]។ ប្រព័ន្ធសមាមាត្រនៅក្នុងប្រទេសកម្ពុជាសម្រាប់ការបោះឆ្នោតសភាជាតិ រដ្ឋសភាជាតិកម្ពុជា និងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ជំរុញឲ្យមានការអនុវត្តប្រព័ន្ធបរិមាណភាគនៃបញ្ជីបេក្ខជនថាជាមធ្យោបាយ មួយដើម្បីជំរុញឲ្យភាពជាតំណាងស្ត្រីមានភាពច្បាស់លាស់នៅក្នុងសង្គមបិតុនិយមខ្លាំង ។ ដើម្បីសម្រេចបាននូវគោល ដៅសហសវត្សន៍ពាក់ព័ន្ធនឹងភាពជាតំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ រដ្ឋសភាជាតិ និងព្រឹទ្ធសភា មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជាសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖

- រដ្ឋសភាជាតិ និងក្រុមប្រឹក្សាឃុំសង្កាត់៖ បរិមាណភាគយេនឌ័រដែលកំណត់ដោយច្បាប់គួរតែអនុវត្តចំពោះបញ្ជី បេក្ខជន ដោយភ្ជាប់ជាមួយយន្តការបន្ថែមដែលចែងអំពីលំដាប់លេខរៀងច្បាស់លាស់ ។ ម.ស.ម.ក សូមផ្តល់ នូវអនុសាសន៍នូវបរិមាណភាគ ៣០ ភាគរយជាក់លាក់ជាជំហ៊ានដំបូងដើម្បីលើកកម្ពស់ភាពជាដំណាងរបស់ ស្ត្រី និងដើម្បីសម្រេចឲ្យបាននូវគោលដៅសហសវត្សន៍ដោយអនុវត្តន៍ប្រព័ន្ធដែលហៅថា “ច្របាច់បញ្ចូល” ដែលបានបញ្ជាក់លម្អិតពីខាងលើដែលតម្រូវឲ្យគណបក្សនយោបាយនានា មានជម្រើសរវាងបេក្ខភាពបុរស និង ស្ត្រី ។ ក្នុងរយៈពេលខ្លី បណ្តាគណបក្សនយោបាយគួរតែអនុម័តនូវបរិមាណភាគយេនឌ័រស្មើគ្រិតិត្តនៅ ក្នុងគោលនយោបាយបក្សរបស់ខ្លួន ។
- ព្រឹទ្ធសភា៖ ដោយសារតែសមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតដោយប្រយោលដោយក្រុមប្រឹក្សាឃុំសង្កាត់ ម.ស.ម.ក សូមផ្តល់នូវអនុវសាសន៍ថា អាសនព្រឹទ្ធសភាបម្រុងដែលកំណត់ដោយច្បាប់យ៉ាងហោចណាស់ មានមួយភាគបីជាសមាជិកស្ត្រី ដោយក្រុមប្រឹក្សាតម្រូវឲ្យបោះឆ្នោតក្នុងបញ្ជីដោយឡែកពីរផ្សេងគ្នា មួយសម្រាប់បេក្ខជនជាបុរស និងមួយទៀតបេក្ខភាពស្ត្រី ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ (+៨៥៥ (០) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល៖ ouvirak@cchrcambodia.org **ឬ កញ្ញា ហ្សូលីយ៉ែត រ៉ូហ្សេឡត (+៨៥៥ (០) ១៥ ៣៥ ០៦ ២០ ឬអ៊ីម៉ែល៖** julietterousselot@cchrcambodia.org ។

Cambodian Center for Human Rights

[25] ដូចខាងលើ

[26] គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងលើស្ត្រី ការផ្តល់អនុសាសន៍ទូទៅ ២៣ (សម័យប្រជុំលើកទី ១៦ ឆ្នាំ ១៩៩៧) Political and Public Life http://www.un.org/womenwatch/daw/cedaw/recommendations/recomm.htm#recom23 [រកបានថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១២]